# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ខែកញ្ញា-តុលា ឆ្នាំ២០១៩ /September-October 2019**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៥ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ១០ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១១ |
| ១.៧. វិស័យសំណង់/Construction | ១៣ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១៥** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១៥ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៦ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៧ |
| **៣. ឧបសម្ព័ន្ធ** | **១៨** |

## ខ្លឹមសារសង្ខេប / Executive summary

១. ក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៩ ការនាំចេញទំនិញ[1] របស់កម្ពុជា សម្រេចបានទំហំទឹកប្រាក់សរុប ១២ ០២៩ លានដុល្លារ (៤៤,៩% ធៀបនឹងផសស[2]) បានកើនឡើង ១៥,៦% ធៀបរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ១៣,៥%។ ទោះបីជាអត្រាកំណើនខ្ពស់ជាងរយៈពេលដូចគ្នាឆ្នាំមុនក៏ពិតមែន ប៉ុន្តែ តួលេខបានបង្ហាញថា ការនាំចេញផលិតផលសំខាន់ៗ ដូចជា ផលិតផលកាត់ដេរនិងស្បែកជើង អង្ករ និងកង់ នៅតែមានការថមថយកំណើន ដែលមានអត្រា ១៥,៥% (កំណើន ១៦,២% ក្នុងឆ្នាំ២០១៨), ៧,៨% (កំណើន ២៤,២% ក្នុងឆ្នាំ២០១៨) និង ៤,៨% (កំណើន ១៣,៧% ក្នុងឆ្នាំ២០១៨) រៀងគ្នា។ ទន្ទឹមនេះ ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗមួយចំនួននៅតែបន្តកំណើនថមថយ បើធៀបនឹងអត្រាកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន លើកលែងតែការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងអាស៊ាន។ ការបន្តរក្សាកំណើនខ្ពស់នៃការនាំចេញ អាចបណ្តាល មកពីកត្តាសំខាន់ៗបីគឺ ១) ការនាំចេញរបស់កម្ពុជាចាប់ផ្តើមពិពិធកម្មទីផ្សារជាបណ្តើរៗ ២) ការដករបាំងពន្ធនាំចេញក្នុងក្របខណ្ឌ ASEAN និង GSP ៣) កំណើននៃការនាំចេញទៅកាន់ប្រទេសចិន ដែលជាទីផ្សារធំបំផុតក្នុងចង្វាក់ផលិតកម្មសកល (Global Value Chain)។ ចំណែកឯ ការនាំចូលមានទំហំទឹកប្រាក់សរុបចំនួន ១៦ ៩៦៣ លានដុល្លារ (៥៦,៧% ធៀបនឹងផសស) បានកើនឡើង ១៩,៧% ទាបជាងកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ២៥,៧%។ **កំណើនថមថយនេះ គឺបណ្តាលមកពីការបន្តធ្លាក់ចុះនៃការនាំចូលផលិតផលវាយនភណ្ឌ (ពិសេសក្រណាត់) ខណៈពេលដែលការនាំចូលផលិតផលសំខាន់ផ្សេងៗទៀតនៅតែបន្តរក្សាបានកំណើនរឹងមាំ។** កំណើននៃការនាំចូល បានបង្ហាញ ១) កំណើនតម្រូវការប្រើប្រាស់ក្នុងស្រុក ទាំង consumption goods និង luxurious goods (យានយន្ត) និង ២) ការបន្តរីកលូតលាស់នៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាពិសេស ពាក់ព័ន្ធនឹងសកម្មភាពផលិតកម្មសម្រាប់ការនាំចេញ និងផ្គត់ផ្គង់ក្នុងស្រុក និងការបន្តកំណើនវិនិយោគលើ វិស័យគន្លឹះ ជាពិសេស សំណង់។

**២.** ក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៩នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបប្រមាណ ៥,៣ លាននាក់ កើនឡើង ៩,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះភ្ញៀវទេសចរចិនមានចំនួន ២ លាននាក់ ឬ៣៨,៣% នៃភ្ញៀវទេសចរអន្តរជាតិសរុប (កើនឡើង ២៤,៤%), វៀតណាម ១៣,៦% (កើនឡើង ១៦,២%), ថៃ ៦,៣% (កើនឡើង ២៦,៤%) និងបន្តបន្ទាប់រួមមាន ឡាវ, កូរ៉េខាងត្បូង, អាមេរិក, ជប៉ុន, ម៉ាឡេស៊ី, បារាំង និងអង់គ្លេស។ ក្នុងកំណើនសរុប ៩,៧%នេះ ភ្ញៀវទេសចរចិនបានចូលរួមចំណែកកំណើន (contribution to growth) ៨,៣%។

**៣.** គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេសសរុប ក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៩នេះ មានចំនួន **១៦៥** គម្រោង កើនឡើង ៤៨ គម្រោង (ភាគច្រើនវិនិយោគក្នុងវិស័យឧស្សាហកម្ម) និងមានទុនវិនិយោគប្រមាណ **៦ ០៦២** លានដុល្លារ បានកើនឡើង ៣១,០៤% (កំណើនភាគច្រើនក្នុងវិស័យទេសចរណ៍ដែលបានទុនពីវិនិយោគិនកម្ពុជា) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ បន្ថែមពីនេះ នៅក្នុងខែតុលានេះ មានគម្រោងវិនិយោគប្រភេទថ្មី២ ក្នុងវិស័យឧស្សាហកម្ម គឺ Cosmetic Products និង Mechanic Assembly។ និន្នាការនេះ បង្ហាញពីវឌ្ឍនភាពនៃកំណើនសហគ្រិនភាពក្នុងស្រុកលើវិស័យទេសចរណ៍ ស្របពេលដែលកំណើនការវិនិយោគក្នុងវិស័យឧស្សាហកម្ម ជាបច្ច័យក្នុងការបង្កើនល្បឿននៃឧស្សាហនីយកម្ម។ ទោះជាយ៉ាងនេះក្តី កំណើនក្នុងវិស័យឧស្សាហកម្មភាគច្រើន បាន

[1] ទិន្នន័យផ្លូវការពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (Admin Data)

[2] ផសស (GDP at current price Million US$) = ២៦ ៧៨៦ លានដុល្លារ÷ យោងតាមតារាងMacro-framework ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

មកពីគម្រោងវិនិយោគលើរោងចក្រកាបូប ដែលបង្ហាញពីភាពមានកម្រិតនៃការធ្វើពិពិធកម្មវិស័យឧស្សាហកម្មនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស។

៤. នៅខែតុលា ឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្មនៅរាជធានីភ្នំពេញ ***បានធ្លាក់ចុះ -0,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។*** បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម ក្នុងខែតុលាឆ្នាំ ២០១៩ នេះ ជារួម បានកើនឡើងក្នុងអត្រា ១,៣% ទាបជាងខែតុលាឆ្នាំមុន ដែលមានអត្រាកំណើន ៣,១%។ កំណើនទាបនេះ ដោយសារការថមថយកំណើនសន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈមិនមានជាតិស្រវឹង (ពី៣,២% មក ១,៥%) និងការធ្លាក់ចុះសន្ទស្សន៍ថ្លៃការដឹកជញ្ជូនក្នុងអត្រាអវិជ្ជមាន ដែលបណ្តាលមកពីការធ្លាក់ចុះថ្លៃប្រេងសាំងនិងប្រេងម៉ាស៊ូត។

៥. គិតត្រឹមខែតុលា ឆ្នាំ២០១៩ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសុរបបានចំនួន **១៩ ៦៨៦,៣** ប៊ីលានរៀល ឬស្មើនឹង **៩៩,៥%** នៃច្បាប់ឆ្នាំ២០១៩ កើនឡើង **២៥,៩%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារកំណើននៃប្រភេទចំណូលសំខាន់ៗមួយចំនួន ដូចជា ចំណូលមិនមែនសារពើពន្ធ **(៣១,២%)**, ចំណូលពីពន្ធប្រយោល **(២៩,០៤%)**, ចំណូលពីពន្ធពាណិជ្ជកម្មក្រៅប្រទេស **(២៥,៥%)** និងចំណូលពីពន្ធផ្ទាល់ **(១៥,៦%)**។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយសុរបបានចំនួន **១៦ ៦៩៦,៩** ប៊ីលានរៀល ឬស្មើនឹង **៦៧,៨%** នៃច្បាប់ឆ្នាំ២០១៩ កើនឡើង **៥,២%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ជាលទ្ធផល គិតត្រឹមខែតុលា ឆ្នាំ២០១៩ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន **៧ ៣៧៣,៤** ប៊ីលានរៀល។ អតិរេកចរន្តនេះ អាចជាបច្ច័យល្អសម្រាប់ការសន្សំថវិកាជាតិ។

៦. ក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៩នេះ សំណើសុំសាងសង់សុរបមានចំនួន ៣ ៨៧២ គម្រោង កើនឡើង ១ ២១៤ គម្រោង ក្នុងផ្ទៃក្រឡា ១៥,២ លានម៉ែត្រការ៉េ កើនឡើង ៣៥,៥% និងមានតម្លៃ ៧,៦ ប៊ីលានដុល្លារ កើនឡើង ៥១,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ការសម្រេចបានកំណើនខ្ពស់នេះ គឺដោយសារកំណើននៃប្រភេទសំណង់ឧស្សាហកម្ម និងលំនៅដ្ឋាន ហើយកំណើននេះ ក៏ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការនាំចូលសម្ភារសំណង់ក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៩នេះដែរ ដែលមានទឹកប្រាក់សុរប ១ ៣១១ លានដុល្លារ ក្នុងអត្រាកំណើន ៦៥,៨%។

៧. គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ រូបិយវត្ថុទូទៅ M2 មានចំនួន ១០១,៩ ទ្រីលានរៀល បានកើនឡើង ២០,៤% ធៀបនឹងឆ្នាំមុន ក្នុងនោះប្រាក់រៀលនៅលើទីផ្សារមានចំនួន ១៧,៥ ទ្រីលានរៀល បានកើនឡើងក្នុងអត្រា ៣០% ធៀបនឹងឆ្នាំមុន។ ប្រាក់រៀលចរាចរលើទីផ្សារមានកំណើនជាមធ្យម ១៨%ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨។

៨. នៅក្នុងខែតុលា ឆ្នាំ២០១៩ ថ្លៃប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា បានកើនឡើងខណៈពេលដែល ថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិ បានធ្លាក់ចុះធៀបនឹងខែមុន។ ថ្លៃអង្ករលេខ១ និងអង្ករលេខ២ លើទីផ្សារកម្ពុជា ពុំមានការប្រែប្រួល រីឯថ្លៃអង្ករលើទីផ្សារអន្តរជាតិ មានការថយចុះធៀបនឹងខែមុន។ ថ្លៃកៅស៊ូគ្រួសារជ័រកៅស៊ូស្ងួត លើទីផ្សារកម្ពុជា មានការកើនឡើងបន្តិច ខណៈពេលដែល នៅលើទីផ្សារអន្តរជាតិ ថ្លៃកៅស៊ូថៃ TSR20 ថយចុះ រីឯកៅស៊ូថៃ RSS3 កើនឡើង បើធៀបនឹងខែមុន។

# ៣. ឧបសម្ព័ន្ធ

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

### ១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ ក្រុម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ

## ១.២. វិស័យហិរញ្ញវត្ថុ / Finance

### ១.២.១. ផ្នែករូបិយវត្ថុនិងធនាគារ

### ១.២.២. ផ្នែកទីផ្សារមូលបត្រ

## ១.៣. វិស័យពាណិជ្ជកម្ម / Trades







ប្រភព÷ GDCE, MEF













ប្រភព÷ GDCE, MEF







ប្រភព÷ GDCE, MEF

## ១.៤. ស្ថានភាពការអនុវត្តថវិការដ្ឋ / Budget execution




ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១.៥. ស្ថានភាពវិនិយោគ / Investment




ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ១.៦. ស្ថានភាពទេសចរណ៍ / Tourism




ប្រភព៖ ក្រសួងទេសចរណ៍

## ១.៧. ស្ថានភាពសំណង់ / Construction




ប្រភព៖ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices




ប្រភព៖ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ប្រភព÷ Association of Natural Rubber Producing Countries (ANRPC)

\

****************************

## <u>**កំណត់សម្គាល់**</u>

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុ សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៩៨ ២២ ៨៤ ៩៤*

*ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*